ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 10 / 04 / 2015
ម៉ោង (Time/Heure): 10:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Sann Rada



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ ព្រហស្បតិ៍ ទី ២៥ ខែ មីនា ឆ្នាំ ២០១៥

## សវនាការលើកស្តាង- ថ្ងៃ ២៦៣

រៀបចំដោយ៖ **សែ កុលវុឌ្ឍី** និង **Maddalena GHEZZI**

| **កំណត់ហេតុអ្នកចូលរួម** |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យ៉ា សុខន, ចៅក្រម Claudia FENZ, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី, ចៅក្រម Martin KAROPKIN |
| ក្រឡាបញ្ជី៖ លោកស្រី សែ កុលវុឌ្ឍី, កញ្ញា Maddalena GHEZZI, លោក Roger PHILLIPS |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក សេង ប៊ុនឃាង, លោក Dale LYSAK, កញ្ញា សុង ឆវ័ន្ត, លោក Vincent de WILDE d'ESTMAEL |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Victor KOPPE, លោក សួន វិសាល |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSE |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ លោកស្រី ទូច វរល័ក្ស, លោក Calvin SAUNDERS |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី Marie GUIRAUD, លោក ឡោ ជុនធី, លោក |

| |
|---|
| វែន ពៅ, លោកស្រី ស៊ីន សុវ៉ន, លោក ហុង គីមសួន, លោកស្រី ម៉ុច សុវណ្ណារី, លោក គីម ម៉េងឃី |
| សាក្សី/ដើមបណ្ដឹងរដ្ឋប្បវេណី៖ លោក សួត្រ សាំង (2-TCCP-304), សឃ សែន (2-TCCP-271) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អរុណ, លោកស្រី សួ សុទ្ធាវី |
| ផ្សេងៗ៖ កញ្ញា សុក សុភ័គមណីកា, លោក វ៉ាត សុម៉ៅ, កញ្ញា ណី សុមេត្តា, លោកស្រី សំ មករា, លោក លី សុតុល្យ, លោក Yassir AL-KHUDAYRI |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៥ | ចាប់ផ្ដើមម៉ោង៖ ០៩.០១ | បញ្ចប់ម៉ោង៖ ១៦.៤១ |
| សម្រាកពេលព្រឹក | ចាប់ផ្ដើមម៉ោង៖ ១០.១២ | បញ្ចប់ម៉ោង៖ ១០.៣០ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្ដើមម៉ោង៖ ១១.៣៣ | បញ្ចប់ម៉ោង៖ ១៣.៣០ |
| សម្រាកពេលរសៀល | ចាប់ផ្ដើមម៉ោង៖ ១៤.៤៥ | បញ្ចប់ម៉ោង៖ ១៥.០៥ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ០៥ ម៉ោង និង ០៥ នាទី |

| **កិច្ចដំណើរការនីតិវិធីផ្សេងទៀត** | | | |
|---|---|---|---|
| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្ដើម | ម៉ោងបញ្ចប់ |
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ<br>ក្រឡាបញ្ជី | ០៩.០២ | ០៩.០៣ |
| សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនក្រោមសាលសវនាការ | មេធាវីការពារក្ដី នួន ជា | ០៩.០៣ | ០៩.០៥ |
| ការតាំងសំណួរទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណី សួត្រ សាំង (2-TCCP-304) | មេធាវីការពារក្ដី នួន ជា<br>មេធាវីការពារក្ដី ខៀវ សំផន<br><br>អង្គជំនុំជម្រះ | ០៩.០៨<br>១០.៤៩<br>១៣.៥៥<br>១៣.៥០ | ១០.៤៩<br>១៣.៤៨<br>១៤.០០<br>១៣.៥៤ |
| សេចក្ដីសម្រេចលើសំណើសុំវិធានការការពារសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណី (2-TCCP-271) | អង្គជំនុំជម្រះ | ១០.៣០ | ១០.៣៣ |
| សំណើសុំឱ្យដាក់ប្រតិចារិកសវនាការជាអសាធារណៈនៃសក្ខីកម្មរបស់ដើមបណ្ដឹង | មេធាវីការពារក្ដី ខៀវ សំផន | ១០.៣៤ | ១០.៣៧ |

| | | | |
|---|---|---|---|
| រដ្ឋប្បវេណី 2-TCCP-271 ជាសាធារណៈ | | | |
| ការថ្លែងទុក្ខសោកវេទនា និងព្យសនកម្ម របស់ដើមបណ្តឹងរដ្ឋប្បវេណី | ដើមបណ្តឹងរដ្ឋប្បវេណី សូត្រ សាំង (2-TCCP-304) | ១៤.០១ | ១៤.០៤ |
| ការតាំងសំណួរទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន (2-TCCP-271) | មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី<br>សហព្រះរាជអាជ្ញា<br>មេធាវីការពារក្តី នួន ជា<br>មេធាវីការពារក្តី ខៀវ សំផន | ១៤.១៣<br><br>១៤.២១<br>១៥.២៧<br>១៥.៥៥ | ១៤.២០<br><br>១៥.២៧<br>១៥.៥៥<br>១៦.៣១ |
| សំណើសុំរបស់មេធាវីការពារក្តី ខៀវ សំផន ក្នុងការសួរតទល់ជាមួយសាក្សី | មេធាវីការពារក្តី ខៀវ សំផន | ១៦.៣២ | ១៦.៣៧ |
| ការថ្លែងអំពីទុក្ខសោកវេទនា និងព្យសនកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី | ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន (2-TCCP-271) | ១៦.៣៧ | ១៦.៣៨ |

**<u>សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

**<u>ការប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី</u>**

ប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ។ ក្រឡាបញ្ជីរាយការណ៍ថា គ្រប់ភាគីទាំងអស់មានវត្តមាន លើកលែងតែ ជនជាប់ចោទ នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួន ក្រោមសាលសវនាការ។

**<u>សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ</u>**

អង្គជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ ដោយតាមដានកិច្ចដំណើរការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួនដែលស្ថិតនៅខាងក្រោមសាលសវនាការ។

**<u>ការតាំងសំណួរទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណី សូត្រ សាំង (2-TCCP-304)</u>**

អង្គជំនុំជម្រះ មេធាវីការពារក្តី នួន ជា និង មេធាវីការពារក្តី ខៀវ សំផន បានបន្តតាំងសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី សូត្រ សាំង (2-TCCP-304)។ បន្ទាប់មក ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ក៏បានថ្លែងអំពីទុក្ខសោកវេទនារបស់ខ្លួន និងព្យសនកម្មដែលខ្លួនបានទទួលរងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យផងដែរ។

**សេចក្តីសម្រេចលើសំណើសុំវិធានការការពារចំពោះដើមបណ្តឹងរដ្ឋប្បវេណី សយ សែន (2-TCCP-271)**

អង្គជំនុំជម្រះ សម្រេចបញ្ឈប់វិធានការការពារសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-271 ដោយការធ្វើសវនាការជាអសាធារណៈ ដោយហេតុថា ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះបានអះអាងថាខ្លួនពុំមានភាពភ័យខ្លាចក្នុងការផ្តល់សក្ខីកម្មជាសាធារណៈនោះទេ។ អង្គជំនុំជម្រះបានរំលឹកដល់ភាគីថា សេចក្តីសម្រេចនេះមិនប៉ះពាល់ទៅនឹងការណែនាំពីមុនដែលពាក់ព័ន្ធនឹងនីតិវិធីសវនាការលើភស្តុតាងទាក់ទងទៅនឹងជនរងគ្រោះនៃការបៀតបៀនលើផ្លូវភេទនោះទេ។

**ការស្នើសុំឱ្យដាក់ប្រតិចារិកនៃសវនាការជាអសាធារណៈរបស់ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-271 នៅថ្ងៃទី ០៥ ខែ កុម្ភៈ ទៅជាសាធារណៈ**

អង្គជំនុំជម្រះអនុញ្ញាតតាមសំណើរបស់មេធាវីការពារក្តី ខៀវ សំផន ដែលបានស្នើសុំឱ្យដាក់ប្រតិចារិកនៃសវនាការជាអសាធារណៈថ្ងៃទី០៥ ខែកុម្ភៈ ទៅជាសាធារណៈដោយសារតែដើមបណ្តឹងរដ្ឋប្បវេណីរូបនេះបានដកសំណើសុំវិធានការការពាររបស់ខ្លួន។

**ការតាំងសំណួរទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន 2-TCCP-271**

មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សហព្រះរាជអាជ្ញា មេធាវីការពារក្តី នួន ជា និងមេធាវីការពារក្តី ខៀវ សំផន បានបន្តតាំងសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី សយ សែន។ បន្ទាប់មកដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ បានថ្លែងពីទុក្ខសោកវេទនា និងព្យសនកម្មដែលខ្លួនបានទទួលរងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ អង្គជំនុំជម្រះបានបង្គាប់ឱ្យដើមបណ្តឹងរដ្ឋប្បវេណី សយ សែន សរសេរអាសយដ្ឋានរបស់បុគ្គលមួយរូបដែលបានបញ្ជាក់នៅក្នុងសក្ខីកម្មរបស់គាត់ "ហាន"។

**សំណើសុំឱ្យមានការសួរទល់គ្នាជាមួយសាក្សី**

មេធាវីការពារក្តី ខៀវ សំផន បានស្នើដល់អង្គជំនុំជម្រះ ឱ្យមានការសួរតទល់រវាងសាក្សីទាំងពីរដោយហេតុតែសក្ខីកម្មរបស់សាក្សីទាំងពីរមានភាពផ្ទុយគ្នា។ សហព្រះរាជអាជ្ញា បានស្នើឱ្យមេធាវីការពារក្តី ខៀវ សំផន ធ្វើសំណើជាលាយលក្ខណ៍អក្សរ។ សហមេធាវីនាំមុខ និង មេធាវីការពារក្តី នួន ជា យល់ស្របទៅនឹងសំណើសុំធ្វើជាលាយលក្ខណ៍អក្សរនេះផងដែរ។ អង្គជំនុំជម្រះបានបង្គាប់ឱ្យមេធាវីការពារក្តី ខៀវ សំផន ដាក់សំណើជាលាយលក្ខណ៍អក្សរមកអង្គជំនុំជម្រះ។

**កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង**

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/5863 | | 00354358-00354368; 00379416-00379424; 01055812-01055824 | Civil party application of Mr. SAUT Saing | C | 00354360 00354361 00354364 00354366 | 00379417 00379418 00379421 00379422 | 01055815 01055816 01055820 01055822 |
| E3/5853 | D40/20 | 00165328-00165336; 00433567-00433575 00524316-00524324 | Written Record of Interview of SAING Sim | P | 00165332 00165334 | 00433571 00433573 | 00524320 00524323 |
| E29/466 | | 01072053-01072056; 01066608-01066609; 01072836-01072838 | Witness Expert Support Unit (WESU) Risk Assessment of SORY Sen | C | 01072056 | 01066609 | N/A |
| E3/2062 | | 00079436-00079442; 00301363-00301370; 00789274-00789282 | Brief history of "Genocidal Site" Kraing Ta Chan of Pol Pot-Ieng Sary Clique, Kus sub-district, Tram Kak district, Takeo province | P | 00079439 | 00301366 | N/A |
| E3/5864 | D40/21 | 00165337-00165343; 00223547-00223552; 00524325-00524332 | Written Record of Interview of SAUT Saing | C | | | |
| E319.1.23 | | 00964478-00964492; 00970112-00970130; 00973084-00973099 | Written Record of Interview of [ Redacted] | S | 00964482 00964487 00964488 | 00970117 00970123 00970124 | 00973088 00973093 00973094 |
| E3/4626 | | 00373463-00373472; 00380131-00380139; 00426201-00426211 | Written Record of Interview of PECH Chim ពេជ្រ ជឹម dated 27-08-2009 | P | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| E319.1.24 | | 00960627-00960641 00969617-00969633; 00973016-00973029 | Strictly Confidential Witness Interview of [Redacted] | S | 00960637 00960640 | 00969628 00969632 | 00973025 00973028 |
| E3/5865 | D22/88A | 00579252 | Supplementary information on civil party applicant | C | 00579252 | N/A | N/A |
| E319.1.33 | | 00968170-00968196; 00980277-00980305; 00982607-00982632 | Written Record of Interview of [Redacted] | S | | | |
| E3/5866 | D125/220.35 | 00365690; 00363331; 00371257 | Plan of site of former Kraing Ta Chan Prison | P | 00365690 | 00363331 | 00371257 |
| E3/5828 | D125/220 | 00365707-00365713; 00363337-00363340; 00371249-00371253 | Report of Execution of Rogatory Letter, dated 17-03-2009 | P | 00365711 | 00366669 | 00371252 |
| E319/20.2 | | 01072285-01072286 | Written Record of Investigation Action | S | N/A | 01072285 | N/A |
| E3/5827 | | 00270855-00270897; 00866424-00866463; 00872799-00872835 | Victim's background | P | 00270874 | 00866433 00866434 | 00872808 00872809 |
| E3/5844 | | 01056208-01056209; 01056614-01056615; 01056616-01056617 | Transcript of Recorded Interview by Investigator with HUN Kimseng | P | 01056209 | 01056615 | 01056617 |
| E3/4846 | | 00527717-00527770; 00527771-00527796; 00943267-00943276 | DC Cam Document "Interview with SOY Sen" | P | 00527748 | 00527786 | 00943276 |
| E3/5867 | D125/220.30 | P00355394 | Photo 29 | P | P00355394 | P00355394 | P00355394 |
| E3/5868 | D125/220.31 | P00355395 | Photo 30 | P | P00355395 | P00355395 | P00355395 |

| **ដីកា/សេចក្ដីសម្រេចផ្ទាល់មាត់៖** |
|---|
| • អនុញ្ញាតឱ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរនីតិវិធីសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ហើយបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ដើម្បីតាមដានសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។(០៩.០៥)<br>• សេចក្ដីសម្រេចលើសំណើសុំវិធានការការពារសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណី 2-TCCP-271 (១០.៣៣)<br>• សម្រេចតាមសំណើរបស់មេធាវីការពារក្ដី ខៀវ សំផន ដែលបានស្នើសុំឱ្យដាក់ប្រតិចារិកនៃសវនាការជាអសាធារណៈ នៅថ្ងៃទី០៥ ខែកុម្ភៈ ទៅជាសាធារណៈវិញ ដោយសារតែមានការដកសំណើសុំវិធានការពារ។ (១០.៣៧)<br>• បង្គាប់ឱ្យបុគ្គលិកផ្នែកសោតទស្សន៍ ភ្ជាប់រូបភាព និង សម្លេង ទៅកន្លែងសាធារណៈបន្ទាប់ពីបញ្ចប់ការតាំងសំណួរទៅសាក្សី សួត្រ សាំង។ (១៤.០៥)<br>• បង្គាប់ឱ្យដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន (2-TCCP-271) សរសេរនូវអាសយដ្ឋានរបស់បុគ្គលម្នាក់ឈ្មោះ "ហាន" ដែលគាត់បានលើកឡើងក្នុងអំឡុងពេលនៃការផ្ដល់សក្ខីកម្ម។ (១៥.៤០)<br>• បង្គាប់ឱ្យមេធាវីការពារក្ដី ខៀវ សំផន ដាក់សំណើសុំសួរតទល់រវាងសាក្សីជាលាយលក្ខណ៍អក្សរមកអង្គជំនុំជម្រះ។ (១៦.៣៧)<br>• បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ត្រឡប់ទៅមន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំខ្លួនគាត់ មកសាលសវនាការវិញឱ្យបានមុនម៉ោង ០៩.០០ ព្រឹក នៅថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥ ។ (១៦.៤១) |

| **កាលវេលាសវនាការបន្ត** |
|---|
| សវនាការនឹងបន្តទៅថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥ ចាប់ផ្ដើមពីម៉ោង ០៩.០០ ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៥

ក្រឡាបញ្ជី ក្រឡាបញ្ជី

សែ គុលឧត្តម Maddalena GHEZZI